**ធនាគារជាតិ នៃ កម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារឆ្នាំ២០១៧ និងទស្សនវិស័យឆ្នាំ២០១៨

រៀបចំដោយ ធនាគារជាតិនៃកម្ពុជា

ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០១៧នេះ បានបន្តរីកចម្រើនល្អប្រសើរ ដែលគាំទ្រដោយភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចនៅប្រទេសអភិវឌ្ឍន៍ ដូចជា សហរដ្ឋអាមេរិក តំបន់អឺរ៉ូ និង ជប៉ុន និងការបង្កើនល្បឿនកំណើនសេដ្ឋកិច្ចនៅប្រទេសកំពុងលូតលាស់និងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស នៅក្នុងតំបន់អាស៊ីដែលបន្តរួមចំណែកប្រមាណពីរភាគបីក្នុងកំណើនសេដ្ឋកិច្ចពិភពលោក។

ភាពអំណោយផលនៃសេដ្ឋកិច្ចពិភពលោកនិងតំបន់ គួបផ្សំនឹងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងវឌ្ឍនភាពនៃការធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងស្រុក បានរួមចំណែកគាំទ្រការរីកចម្រើនវិស័យសេដ្ឋកិច្ចចម្បងៗរបស់កម្ពុជា ជាពិសេសវិស័យកាត់ដេរ (៧%) សំណង់ (១៨%) និងទេសចរណ៍ (៥%)។ ក្នុងបរិការណ៍នេះ នៅឆ្នាំ២០១៧ សេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនល្អប្រសើរក្នុងអត្រា ៦,៩% ជាមួយនឹងការរក្សាបានស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុរឹងមាំ។ ជញ្ជីងទូទាត់កម្ពុជាបន្តមានអតិរេក ហើយបានគរពូនទុនបម្រុងអន្តរជាតិឱ្យកើនឡើងដោយអាចធានាការនាំចូលទំនិញនិងសេវាបានប្រមាណ ៦ខែ ដែលជាកម្រិតមួយខ្ពស់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ អត្រាអតិផរណាជាមធ្យមមានកម្រិត ២,៩% ដែលជាកម្រិតអាចគ្រប់គ្រងបាន និងឆ្លុះបញ្ចាំងពីការរក្សាបានស្ថិរភាពថ្លៃក្នុងកម្រិតសមស្របសម្រាប់ការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច។ ការសម្រេចបានស្ថិរភាពថ្លៃជារួម គឺដោយសារការរួមចំណែកនៃការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន និងមានសង្គតិភាពជាមួយគោលនយោបាយសារពើពន្ធ តាមរយៈការរក្សាល្បឿនកំណើនការផ្គត់ផ្គង់រូបិយវត្ថុសមស្រប (ប្រមាណ ២៣%) និងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ប្រមាណ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក ទោះក្នុងបរិបទដុល្លាររូបនីយកម្មខ្ពស់ក្តី។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាបានខិតខំលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ តាមរយៈការពង្រឹងឧបករណ៍គោលនយោបាយរូបិយវត្ថុនិងការប្រើប្រាស់ប្រាក់រៀល ដោយបានបន្តអភិវឌ្ឍមូលបត្រអាចជួញដូរបាន (NCD) និងបន្តដាក់ឱ្យដំណើរការនូវប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)។ ប្រតិបត្តិការ LPCO បានផ្តល់នូវផ្លែផ្កាប្រកបដោយភាពវិជ្ជមាន ដោយបានរួមចំណែកផ្តល់សន្ទនីយភាពជាប្រាក់រៀលក្នុងតម្លៃមួយទាបសមរម្យដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានកង្វះខាតប្រាក់រៀលនៅក្នុងប្រតិបត្តិការរបស់ខ្លួន ដែលនេះបានរួមចំណែកក្នុងការកាត់បន្ថយគម្លាតអត្រាការប្រាក់ជារៀលនិងដុល្លារអាមេរិកគួរឱ្យកត់សម្គាល់។ ទន្ទឹមនេះការដាក់ពិដានអត្រាការប្រាក់ ១៨% ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងឥណទានជនបទ ក៏បានរួមចំណែកកាត់បន្ថយអត្រាការប្រាក់ឥណទានខ្នាតតូចនិងមធ្យម ហើយបានរួមចំណែកលើកស្ទួយជីវភាពប្រជាជនក្រីក្រនៅតាមជនបទ ដែលមានតម្រូវការឥណទានប្រកបអាជីវកម្ម។ គួរបញ្ជាក់ថា ការកំណត់ពិដានអត្រាការប្រាក់បានជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងឥណទានជនបទធ្វើទំនើបកម្មសេវាហិរញ្ញវត្ថុរបស់ខ្លួនផងដែរ ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការនានា។

ទន្ទឹមនេះ វិស័យធនាគារនៅក្នុងឆ្នាំ២០១៧ បន្តមានវឌ្ឍនភាពរឹងមាំនិងបរិយាប័ន្ន ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២០,២% កំណើនប្រាក់បញ្ញើអតិថិជន ២៤,៥% និងកំណើនឥណទាន ១៨%។ គួរបញ្ជាក់ថា អត្រាកំណើនឥណទានបានថយចុះជាបន្តបន្ទាប់ក្រោយពីបានកើនឡើងខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ (ប្រមាណ ៣០%) ស្របតាមវដ្តនៃកំណើនដែលផ្តើមចេញពីមូលដ្ឋានតូច ស្ថានភាពទីផ្សារ និងឥទ្ធិពលនៃវិធានការម៉ាក្រូប្រុងប្រយ័ត្ន។ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុមានសុខភាពល្អ ដោយអនុបាតសាធនភាពជាមធ្យមមានប្រមាណ ២៣% និង ២២% រៀងគ្នា ខ្ពស់ជាងកម្រិតអប្បបរមា ១៥% និងអនុបាតសន្ទនីយភាពប្រមាណ ១៣៩% (គ្រឹះស្ថានធនាគារពាណិជ្ជ) និង ១៧២% (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) ខ្ពស់ជាងកម្រិតអប្បបរមា ៧០% ខណៈដែលឥណទានមិនដំណើរការស្ថិតក្នុងកម្រិតសមស្របប្រមាណ ២,៤% (គ្រឹះស្ថានធនាគារ) និង ២% (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ)។ ការរីកចម្រើននៃវិស័យធនាគារនិងជំនឿទុកចិត្តលើការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា បាននាំមកនូវការបោះទីតាំងអាជីវកម្មរបស់ធនាគារធំៗបរទេសមួយចំនួននៅកម្ពុជាក្នុងឆ្នាំ២០១៧ ដូចជាធនាគារ BRED, MIZUHO និង Bank of Canada។ ប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃប្រតិបត្តិការទូទាត់តាមអេឡិចត្រូនិក ដូចជាការទិញ-លក់អនឡាញ (E-commerce) និងការកើនឡើងការប្រើប្រាស់ QR code សម្រាប់ការទូទាត់។ តួយ៉ាង ប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (Fast Payment) ដែលជាប្រព័ន្ធទូទាត់រាយអេឡិចត្រូនិកភ្លាមៗ ត្រូវបានប្រើប្រាស់ពេញលេញដោយគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ កាលពីដំណាច់ឆ្នាំ២០១៧ ហើយប្រព័ន្ធ Cambodian Shared Switch ត្រូវបានចាប់ផ្តើមដាក់ឱ្យប្រើប្រាស់ ដើម្បីអនុញ្ញាតឱ្យអតិថិជននៃគ្រឹះស្ថានធនាគារមួយប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធជាមួយម៉ាស៊ីន ATM និងម៉ាស៊ីន POS របស់គ្រឹះស្ថានដទៃទៀត។ លើសពីនេះ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាទូទាត់អេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជាបានសម្រេចលើកកម្ពស់ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់ ដោយបានផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានទាំងនេះឱ្យធ្វើប្រតិបត្តិការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ ដែលការណ៍នេះនឹងផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានអាចអភិវឌ្ឍនិងដាក់ឱ្យប្រើប្រាស់សេវាកម្មថ្មីៗ ដោយស្ថិតក្រោមការគ្រប់គ្រងគ្រប់ជ្រុងជ្រោយជាងមុន។ វិស័យធនាគារជារួមបានបន្តរួមចំណែកគាំទ្រកំណើនសកម្មភាពសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ ដោយបានបង្កើនបរិយាប័ន្នហិរញ្ញវត្ថុដល់ប្រមាណ ៥៦% (ចំនួនប្រជាជនពេញវ័យដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុ ធៀបនឹងចំនួនប្រជាជនពេញវ័យសរុប)។ ទន្ទឹមនេះ ដើម្បីឱ្យវិស័យធនាគារអភិវឌ្ឍប្រកបដោយចីរភាពក្នុងរយៈពេលវែង ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បញ្ចូលការអប់រំផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីអប់រំចំណេះដឹងទូទៅរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ចំណេះដឹងរបស់សាធារណជនលើការប្រើប្រាស់សេវាហិរញ្ញវត្ថុឱ្យចំគោលដៅ និងមានប្រសិទ្ធភាព។ ដើម្បីចូលរួមការពារផលប្រយោជន៍អតិថិជនមួយកម្រិតថែមទៀត ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ Hotline ចំនួន ២៦ ខ្សែ និងបានដោះស្រាយបញ្ហាជាបន្តបន្ទាប់។

ចំពោះទស្សនវិស័យអនាគតនៅឆ្នាំ២០១៨នេះ សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងសម្រេចបានក្នុងកំណើនខ្ពស់ ដោយយោងតាមការប៉ាន់ស្មានរបស់រាជរដ្ឋាភិបាល កំណើនសេដ្ឋកិច្ចនឹងអាច

បន្តទទួលបានអត្រាខ្ពស់ប្រមាណ ៦,៩% ស្មើនឹងឆ្នាំ២០១៧ដែរ ទន្ទឹមនឹងការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិក្នុងអត្រា ៦,៨% ធនាគារពិភពលោក ៦,៩% និងធនាគារអភិវឌ្ឍន៍អាស៊ី ៧,១% ដោយផ្អែកលើកម្លាំងគាំទ្រពីក្នុងស្រុកនិងខាងក្រៅ។ កត្តាខាងក្រៅដែលគាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចកម្ពុជារួមមាន៖ i/- ការបន្តងើបឡើងនៃកំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ដូចជាប្រទេសនាំទំនិញចូលពីកម្ពុជា និងភាពរឹងមាំនៃកំណើនក្នុងតំបន់ដែលនឹងគាំទ្រដល់ការវិនិយោគការនាំចេញ និងវិស័យទេសចរណ៍ ii/- កំណើនការនាំចេញសម្លៀកបំពាក់និងស្បែកជើងដែលគាំទ្រដោយការបន្តទទួលបានប្រព័ន្ធអនុគ្រោះពន្ធពីសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក និងកំណើនការនាំចេញទៅកាន់ប្រទេសជប៉ុននិងកាណាដា ដែលធ្វើឱ្យកម្ពុជាអាចកាត់បន្ថយការពឹងផ្អែកការនាំចេញទៅតំបន់តែមួយចំនួនតូច និង iii/- ការធ្វើពិពិធកម្មផលិតផលនាំចេញ ដូចជាការបង្កើនការនាំចេញអង្ករ គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់រថយន្ត ជាដើម។ ទន្ទឹមនេះ កត្តាថាមវន្តខាងក្នុងចម្បងៗជំរុញកំណើនសេដ្ឋកិច្ចមានដូចជា៖ i/- ការបន្តរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ii/- ការរីកចម្រើនវិស័យធនាគារប្រកបដោយបរិយាប័ន្ន iii/- កំណើននៃចំណូលថវិការដ្ឋនិងការបង្កើនប្រាក់ខែរបស់មន្ត្រីរាជការ និង iv/- ការបន្តទទួលបានផ្លែផ្កានៃការកែទម្រង់ស៊ីជម្រៅនិងការអនុវត្តគោល-នយោបាយគាំទ្រនានាលើគ្រប់វិស័យ។

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបន្តមានភាពរឹងមាំ ដោយផ្អែកលើការរំពឹងពីស្ថានភាពល្អប្រសើរនៃជញ្ជីងទូទាត់និងស្ថិរភាពថ្លៃ។ ជញ្ជីងទូទាត់កម្ពុជាត្រូវបានរំពឹងថាបន្តមានអតិរេក ដោយសារការថយចុះនៃឱនភាពគណនីចរន្តដែលគាំទ្រដោយការកើនឡើងនៃការនាំចេញសម្លៀកបំពាក់ និងផលិតផលមិនមែនកាត់ដេរ ព្រមទាំងការបន្តហូរចូលនៃវិនិយោគផ្ទាល់បរទេស ដែលទាក់ទាញដោយភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចនិងការរីកចម្រើនរបស់កម្ពុជា។ ការបន្តមានអតិរេកជញ្ជីងទូទាត់នឹងគរពូនទុនបម្រុងអន្តរជាតិដល់ប្រមាណ ៦,៥ ខែនៃការនាំចូលទំនិញនិងសេវា ដែលនឹងរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិនបរទេសមកលើកម្ពុជាផងដែរ។ អត្រាអតិផរណាមធ្យមសម្រាប់ឆ្នាំ២០១៨ត្រូវបានរំពឹងថានឹងបន្តមានកម្រិតទាប អាចគ្រប់គ្រងបានប្រមាណ ៣% ដែលធានាឱ្យមានស្ថិរភាពថ្លៃល្អប្រសើរ។ កម្រិតទាបនៃអត្រាអតិផរណាគឺដោយសារការព្យាករពីកំណើនយឺតនៃការឡើងថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ ស្ថិតក្នុងស្ថានភាពដែលតម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងស្ថិតក្នុងរង្វង់ប្រមាណ ៤.០៣៧ រៀលក្នុងមួយដុល្លារអាមេរិក ហើយកំណើនឥណទានទៅកាន់វិស័យឯកជនមានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១៧។ ការផ្គត់ផ្គង់រូបិយវត្ថុ (M2) ត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ១៩% ដែលមិនបង្កឱ្យមានសម្ពាធដល់អតិផរណា ក្នុងនោះរូបិយវត្ថុក្នុងចរាចរណ៍និងប្រាក់បញ្ញើជារៀលត្រូវបានរំពឹងថាមានកំណើន ២១% និង ២៧% រៀងគ្នា ហើយប្រាក់បញ្ញើជារូបិយប័ណ្ណ (FCD) មានកំណើន ១៩%។

ទោះយ៉ាងណាក៏ដោយ សេដ្ឋកិច្ចកម្ពុជាអាចប្រឈមនឹងហានិភ័យមួយចំនួន ជាពិសេសហានិភ័យពីខាងក្រៅ រួមមាន៖ i/- កំណើនសេដ្ឋកិច្ចតំបន់អឺរ៉ូអាចនឹងថយល្បឿនមកវិញ ដោយសារហានិភ័យនៃភាពមិនប្រាកដប្រជានៃជំហរគោលនយោបាយចំពោះដៃគូពាណិជ្ជកម្ម ក្រោយពីការចាកចេញរបស់អង់គ្លេស (Brexit) និងហានិភ័យក្នុងវិស័យធនាគារនិងបំណុលសាធារណៈដែលមិនទាន់បានបញ្ចប់នៅឡើយ។ ការថយចុះកំណើនតំបន់អឺរ៉ូនឹងអាចមានផលប៉ះពាល់ដល់ការនាំចេញរបស់

កម្ពុជា ជាពិសេសផលិតផលកាត់ដេរ ដោយសារកម្ពុជានាំចេញទៅទីផ្សារអឺរ៉ុបលើសពីមួយភាគបីនៃការនាំចេញសរុប ii/- ភាពមិនច្បាស់លាស់លើការអនុវត្តគោលនយោបាយរបស់សហរដ្ឋអាមេរិក ដែលបង្កឱ្យមានភាពមិនប្រាកដប្រជាក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិនិងតំបន់ ដែលជាប្រភពលំហូរមូលធនសម្រាប់កម្ពុជា iii/- ការរំពឹងទុកថាប្រាក់ដុល្លារអាមេរិកនឹងកើនថ្លៃ ដែលអាចប៉ះពាល់ដល់ភាពប្រកួតប្រជែងនៃផលិតផលនាំចេញរបស់កម្ពុជា ដោយសារតែកម្ពុជាមានកម្រិតដុល្លារូបនីយកម្មខ្ពស់ iv/- ការកើនឡើងភាពគំរាមកំហែងលើទីផ្សារនាំចេញក្នុងវិស័យកាត់ដេររបស់កម្ពុជា ដោយសារគោលនយោបាយគាំពារនិយម និងកិច្ចព្រមព្រៀងទ្វេភាគីរបស់សហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិកជាមួយប្រទេសដែលនាំចេញផលិតផលកាត់ដេរ ហើយប្រសិនបើកិច្ចព្រមព្រៀងអន្តរប៉ាស៊ីហ្វិកមិនមានសហរដ្ឋអាមេរិក (TPP minus US) អាចនឹងត្រូវអនុវត្តនាពេលអនាគត នោះការគំរាមកំហែងអាចនឹងកើនឡើងថែមទៀត និង v/- ហានិភ័យនៃការថយចុះលឿនជាងការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចចិន ដែលអាចបង្កផលប៉ះពាល់មួយចំនួនដល់សេដ្ឋកិច្ចកម្ពុជា ដូចជា វិស័យទេសចរណ៍ ពាណិជ្ជកម្ម និងវិនិយោគ ជាដើម។ ម៉្យាងទៀត កម្ពុជាក៏បន្តមានបញ្ហាប្រឈមនឹងហានិភ័យខាងក្នុងផងដែរ រួមមាន៖ i/- ការអាចបន្តថយល្បឿនកំណើនវិស័យសំណង់ បន្ទាប់ពីមានកំណើនការផ្គត់ផ្គង់ខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ii/- ការដំឡើងប្រាក់ខែក្នុងវិស័យកាត់ដេរ ដែលអាចមានផលប៉ះពាល់ដល់ការប្រកួតប្រជែងការនាំចេញរបស់កម្ពុជា iii/- កង្វះទីផ្សារផលិតផលកសិកម្ម ដែលអាចធ្វើឱ្យតម្លៃកសិផលចុះទាបខ្លាំង និង iv/- ដូចដែលបានសង្កេតឃើញរាល់ពេលមុនការបោះឆ្នោតសកល ការវិនិយោគអាចមានការថយចុះដោយសារ "អត្តចរិតរបស់វិនិយោគិនរង់ចាំមើលមុននឹងសម្រេចបង្កើនការវិនិយោគ (Wait and See Attitudes of Investors)" ដូច្នេះនៅដើមឆ្នាំ២០១៨នេះ ការវិនិយោគក៏អាចប្រឈមនឹងហានិភ័យថយចុះផងដែរ។ ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជាក៏បន្តមានបញ្ហាប្រឈមរចនាសម្ព័ន្ធ ដូចជា៖ i/- ហេដ្ឋារចនាសម្ព័ន្ធនៅតែទាមទារការអភិវឌ្ឍបន្ថែម ii/- ថ្លៃខ្ពស់នៃអគ្គិសនីធៀបនឹងប្រទេសក្នុងតំបន់ ដែលធ្វើឱ្យថ្លៃដើមផលិតកម្មខ្ពស់ iii/- ដុល្លារូបនីយកម្មស្ថិតក្នុងកម្រិតខ្ពស់ ដែលបន្តដាក់កំហិតលើប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ និង iv/- កង្វះសមត្ថភាពជំនាញដែលចាំបាច់ក្នុងការធ្វើពិពិធកម្មផលិតកម្ម។

ដើម្បីរួមចំណែកគាំទ្រកំណើនប្រកបដោយចីរភាពនិងបរិយាប័ន្ន ស្របតាមគោលនយោបាយចតុកោណដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុដោយភាពប្រុងប្រយ័ត្ន និងអភិវឌ្ឍវិស័យធនាគារ សំដៅរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ និងការធ្វើអន្តរការិយកម្មហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តវិធានការលើកកម្ពស់ប្រសិទ្ធភាពឧបករណ៍គោលនយោបាយដែលមានស្រាប់ និងអភិវឌ្ឍឧបករណ៍ថ្មីៗផ្អែកលើយន្តការទីផ្សារ។ ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារនឹងត្រូវបន្តអភិវឌ្ឍដោយពង្រឹងការប្រើប្រាស់មូលបត្រអាចជួញដូរបាន (NCD) ជាពិសេស សម្រាប់ធ្វើជាឧបករណ៍ធានាក្នុងប្រតិបត្តិការអន្តរធនាគារ និងការអភិវឌ្ឍប្រព័ន្ធសម្រួលប្រតិបត្តិការអន្តរធនាគារ ដូចជា ផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) និងប្រព័ន្ធធនាគារអនឡាញ (Online Banking System) ជាដើម ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយធ្វើប្រតិបត្តិការ ជាមួយគ្រឹះស្ថានមួយទៀតកាន់តែងាយស្រួលនិង

ឆាប់រហ័ស។ ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) នឹងបន្តរៀបចំឡើងដើម្បីផ្តល់សន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្រាប់បង្កើនប្រតិបត្តិការជាប្រាក់រៀល សំដៅរួមចំណែកបន្ទាបអត្រាការប្រាក់ជារៀលនិងជួយដល់ប្រជាកសិករ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តលើកទឹកចិត្តដល់គ្រប់វិស័យ ជាពិសេសវិស័យឯកជនលើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ បន្ថែមលើវឌ្ឍនភាពដែលទទួលបានកន្លងមក ដូចជាការបិទស្លាកតម្លៃជាប្រាក់រៀល ការទូទាត់និងការបើកប្រាក់ខែជាប្រាក់រៀល ជាដើម។

ធនាគារជាតិនៃកម្ពុជានឹងបន្តលើកកម្ពស់និងពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ ទាំងមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្ន ដើម្បីរក្សាសុវត្ថិភាពវិស័យធនាគារ ក្នុងគោលដៅគាំទ្រការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ តាមរយៈការបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងរក្សាស្ថិរភាពវិស័យធនាគារឱ្យបានរឹងមាំ។ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងឆ្នាំ២០១៨នេះ រំពឹងថានឹងបន្តកើនឡើងប្រមាណ ២០% ដែលគាំទ្រដោយកំណើនដើមទុនកំណើនមូលនិធិកម្ចី និងកំណើនប្រាក់បញ្ញើអតិថិជន។ ឥណទានទៅកាន់វិស័យឯកជនរំពឹងមានកំណើនសមស្របជាមធ្យមប្រមាណ ១៧% ស្របពេលដែលប្រាក់បញ្ញើអតិថិជននឹងមានកំណើនប្រមាណ ២៥%។ ស្ថានភាពដើមទុននឹងបន្តពង្រឹងថែមទៀត ដោយដើមទុននឹងត្រូវដំឡើងគ្រប់ចំនួនតម្រូវដោយបទប្បញ្ញត្តិនៅត្រឹមខែមីនា ឆ្នាំ២០១៨។

ធនាគារជាតិនៃកម្ពុជានឹងគាំទ្រការពង្រីកវិសាលភាពនៃការចែករំលែកព័ត៌មានឥណទាន រួមបញ្ចូលទាំងព័ត៌មានឥណទានរបស់ក្រុមហ៊ុន-សហគ្រាសផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធវិស័យធនាគារនឹងត្រូវបន្តអភិវឌ្ឍ ជាពិសេស ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅកម្ពុជា ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech)។ ប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធ Cambodian Shared Switch (CSS) នឹងត្រូវបន្តពង្រឹងជាមួយនឹងការសិក្សាពីលទ្ធភាពនៃការបង្កើតប្រព័ន្ធទូទាត់ដុលភ្លាមៗ ព្រមទាំងរៀបចំយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា។ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់កាន់តែសម្បូរបែប នឹងជួយឱ្យការទូទាត់ធ្វើឡើងប្រកបដោយសុវត្ថិភាព ឆាប់រហ័ស និងចំណាយសមស្រប ព្រមទាំងរួមចំណែកជំរុញបរិយាប័ន្នហិរញ្ញវត្ថុឱ្យកើនបន្ថែមទៀត។ ទន្ទឹមនេះ ក្របខ័ណ្ឌបទប្បញ្ញត្តិ និងយន្តការគ្រប់គ្រងនិងត្រួតពិនិត្យនឹងត្រូវលើកកម្ពស់ សំដៅគ្រប់គ្រងហានិភ័យដែលអាចបណ្តាលមកពីការទូទាត់។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងសមាហរណកម្មវិស័យធនាគារកម្ពុជាទៅក្នុងតំបន់ ក៏ដូចជាពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុតំបន់ តាមរយៈកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទ្វេភាគី អាស៊ាន និងអាស៊ាន+៣ ដើម្បីធ្វើឱ្យវិស័យធនាគារនៅកម្ពុជាកាន់តែអភិវឌ្ឍប្រកបដោយភាពរឹងមាំនិងសមាហរណកម្ម។